# សេចក្តីប្រកាសព័ត៌មាន

## មហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ី

## កម្មវិធីប្រឡងជ្រើសរើសវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជា

ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៥

កម្មវិធីប្រឡងជ្រើសរើសវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសកម្ពុជាលើកទី៧នៃមហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ី ត្រូវបានប្រារព្ធធ្វើឡើងយ៉ាងជោគជ័យនៅថ្ងៃ០៩ ខែកញ្ញា ឆ្នាំ២០១៥ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា.ជប៉ុន (CJCC)។

កម្មវិធីប្រឡងជ្រើសរើសវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រក្នុងប្រទេសនេះ ត្រូវបានរៀបចំឡើងដោយស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា រួមសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន។ ប្រធានបទដែលត្រូវបកស្រាយក្នុងឆ្នាំនេះគឺ “ពេលអ្នកសប្បាយចិត្ត”។ នៅក្នុងការប្រកួតនេះ គឺមានភាពយន្តខ្នាតខ្លីចំនួន៥៣រឿងមកពីវិទ្យាល័យនៅក្នុងនិងជុំវិញទីក្រុងភ្នំពេញបានដាក់ពាក្យចូលរួមប្រកួតប្រជែងនៅក្នុងការប្រកួតនេះហើយក្នុងនោះយើងបានជ្រើសរើសភាពយន្តចំនួន១៦រឿងដើម្បីចាក់បញ្ចាំងនៅក្នុងការប្រកួតក្នុងប្រទេស។



Photo Session at the Awarding Ceremony

មហោស្រពភាពយន្តកុមារ ត្រូវបានចាប់ផ្តើមឡើងនៅប្រទេសជប៉ុនតាំងពីឆ្នាំ២០០៧មកម្លេះ ហើយចាប់តាំងពីពេលនោះមកមហោស្រពនេះត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ។ ដោយឡែកចាប់តាំងពីឆ្នាំ២០០៩មក សិស្សានុសិស្សកម្ពុជាត្រូវបានអញ្ជើញអោយចូលរួមក្នុងមហោស្រពនេះ។ ក្នុងឆ្នាំនេះ សិស្សចំនួន៩នាក់មកពីក្រុមដែលទទួលបានជ័យលាភីទាំង៣ក្រុមត្រូវបានអញ្ជើញអោយចូលរួមជាមួយ និងសិស្សានិស្សមកពីប្រទេសអាស៊ានទាំង១០ ដែលក្នុងនោះមានប្រទេសកម្ពុជា ឥណ្ឌូណេស៊ីសឹង្ហបូរី ថៃឡង់ដ៏ ហ្វីលីពីន ឡាវ ភូមា ប្រ៊ុយណេ វៀតណាម ម៉ាឡេស៊ី ព្រមទាំងទីម័រខាងកើត ចិន កូរ៉េខាងត្បូង ម៉ុងហ្គោល ប្រទេសចិនតៃវ៉ាន់ និងជប៉ុន។ ពួកគេនឹងចូលរួមនៅក្នុងជុំផ្តាច់ព្រ័ត្រនៃមហោស្រពនេះនៅទីក្រុងគីតាមិ កោះហុកកៃដូ នៃប្រទេសជប៉ុននៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៥។

តាមរយៈបទពិសោធក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងផុតទៅ យើងសង្ឃឹមថា សិស្សានុសិស្សកម្ពុជានឹងទទួលបានជោគជ័យនៅក្នុងមហោស្រពនេះ ព្រមទាំងរីករាយក្នុងចងមិត្តភាពជាមួយសិស្សានុសិស្សដែលចូលរួមមកពីបណ្តាប្រទេសផ្សេងៗទៀត។

**ភាពយន្តខ្លីដែលបានជ្រើសរើសដើម្បីចូលរួមក្នុងជុំផ្តាច់ព្រ័ត្រនៃមហោស្រពភាពយន្តកុមារអន្តរជាតិអាស៊ីគឺមានរាយនាមដូចខាងក្រោម៖**

| Prize | Name of Student | Film Titles | High School |
|---|---|---|---|
| 1st | Ly Tongyean<br>Thai Vilak<br>Hong Sunchhay | 2 Orphans | Chbar Ampov High School |
| 2nd | Sok Pich Visoth<br>Phuk Sopheaktra<br>Preap Pichraksmey | When You are Happy | Cambodia Adventist School |
| 3rd | Phal Chanpunloeu<br>Ros Bonavuth<br>Chear Virakyuth | Open Your Mind | Singapore International School |